ប្រទេស សិង្ហបុរី ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# សិក្ខាសាលាស្តីពី "របបពន្ធធានារ៉ាប់រងលើជីវិត" នៅប្រទេសសិង្ហបុរី ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំប្រតិភូនៃអគ្គនាយដ្ឋានពន្ធដារ ចូលរួមក្នុងសិក្ខាសាលាស្តីពី "របបពន្ធធានារ៉ាប់រងលើជីវិត" នៅប្រទេសសិង្ហបុរី ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **ខួន សុខា** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍របស់បណ្តាប្រទេសមួយចំនួនក្នុងតំបន់ ជាពិសេសសឹង្ហបុរី ទាក់ទងនឹងការគ្រប់គ្រង និងប្រមូលពន្ធពីវិស័យធានារ៉ាប់រងលើជីវិត។

សិក្ខាសាលានេះរៀបចំឡើង ដោយសមាគមធានារ៉ាប់រងកម្ពុជា (IAC) និងមានការចូលរួមពីមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ សមាគមធានារ៉ាប់រងកម្ពុជា សមាគមធានារ៉ាប់រងសិង្ហបុរី និងតំណាងមកពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត នៅប្រទេសកម្ពុជា សិង្ហបុរី និងក្នុងតំបន់។ បន្ថែមពីនេះ ក៏មានការចូលរួមពីអ្នកជំនាញការមកពីអាជ្ញាធរចំណូលក្នុងស្រុកសិង្ហបុរី (Inland Revenue Authority of Singapore-IRAS) និងក្រុមហ៊ុន PwC ថ្នាក់តំបន់។ នេះគឺជាព្រឹត្តិការណ៍ ទី២ ដែលរៀបចំដោយ សមាគមធានារ៉ាប់រងកម្ពុជា ខណៈដែលទីមួយគឺនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៧ ស្តីពី «ការចែករំលែករបបពន្ធ លើការធានារ៉ាប់រង» ដែលបាន

ប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត កែន សម្បត្តិ បានគូស បញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏វៃឈ្លាស ពោរពេញដោយគតិបណ្ឌិត និងបញ្ញាញាណដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តែងយកចិត្តទុកដាក់លើការអភិវឌ្ឍ លើគ្រប់វិស័យ រួមទាំងការលើកកម្ពស់សុខុមាលភាព ជីវភាព និង សំណាញ់សុវត្ថិភាពរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាល ក៏ បានជំរុញកិច្ចអភិវឌ្ឍវិស័យធានារ៉ាប់រង ទន្ទឹមនឹងការធានានូវ ប្រសិទ្ធភាពនៃការប្រមូលពន្ធពីវិស័យនេះ ស្របតាមយុទ្ធសាស្ត្រ និងគោលនយោបាយនានា ដូចជា យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣, យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ ជាដើម។ នាពេលថ្មីៗនេះ សម្តេចតេជោ នាយករដ្ឋមន្ត្រី បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវក្របខ័ណ្ឌ គោលនយោបាយជាតិ គាំពារសង្គម ឆ្នាំ២០១៦-២០២៥។ ទន្ទឹម នឹងនេះ ឯកឧត្តមបណ្ឌិត បានលើកឡើងបន្ថែមថា ក្នុងនាមជា សេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន-ពន្ធដារ បាននិងកំពុងបន្តបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយ ចីរភាព និងសម្រេចបាននូវការប្រមូលពន្ធ ជាមួយនឹងកំណើន ខ្ពស់ ប្រកបដោយចីរភាព និងសមធម៌។ កំណែទម្រង់ និង ទំនើបកម្មរដ្ឋបាលសារពើពន្ធ គឺជាការងារអាទិភាពមួយ ពីព្រោះ នេះ នឹងរួមចំណែកក្នុងការធានាបាន នូវភាពសមធម៌ និង ប្រសិទ្ធភាពនៃការប្រមូលពន្ធ។

ឯកឧត្តមបណ្ឌិត កែន សម្បត្តិ បានថ្លែងអំណរគុណ ចំពោះ សមាគមធានារ៉ាប់រងកម្ពុជាដែលបានរៀបចំសិក្ខាសាលាដ៏មាន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

សារៈប្រយោជន៍នេះ និងចំពោះវាគ្មិនមកពីសមាគមធានារ៉ាប់រង សឹង្ហបុរី, អាជ្ញាធរចំណូលក្នុងស្រុករបស់សឹង្ហបុរី និង PwC ដែល បានធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍អំពីបញ្ហា ពន្ធដារលើអាជីវកម្មធានារ៉ាប់រងអាយុជីវិត ពីប្រទេសសិង្ហបុរី និង ប្រទេសមួយចំនួនក្នុងតំបន់ ជាពិសេសលើ៖

- បទប្បញ្ញត្តិ និងបទដ្ឋានអន្តរជាតិនៃរបបពន្ធធានារ៉ាប់រង អាយុជីវិត
- ភាពខុសគ្នារវាងរបបពន្ធលើក្រុមហ៊ុនធានារ៉ាប់រងអាយុ ជីវិតនឹងលើក្រុមហ៊ុនធានារ៉ាប់រងទូទៅ
- ការគណនាប្រាក់បំរុងសម្រាប់គោលបំណងកាត់កងពន្ធ
- ផលប៉ះពាល់នៃរបបពន្ធ លើកំណើនធានារ៉ាប់រងអាយុ ជីវិតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម

ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត កែន សម្បត្តិ បានផ្តល់ជា អនុសាសន៍ដល់ប្រតិភូមកពីអគ្គនាយកដ្ឋានពន្ធដារ និងអគ្គ-នាយដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុដើម្បីយកធាតុចូលដែលទទួល បានពីសិក្ខាសាលានេះ មកពិចារណាក្នុងរៀបចំវិធាននិងនីតិវិធី នៃការបង់ពន្ធលើប្រាក់ចំណូល សម្រាប់សហគ្រាសធានារ៉ាប់រង អនុលោមតាមច្បាប់ស្តីពីពីសារពើពន្ធជាធរមាន៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ